ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៩៤៦ មស.នក

## ជម្រាបជូន
## លោកជំទាវអភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន

**កម្មវត្ថុ** ៖ ស្តីពីការបង្វែរសំណុំរឿងនៃពាក្យបណ្តឹងតវ៉ារបស់ លោក **ខឹម មុនីកុសល** ភេទប្រុស អាយុ៤៨ឆ្នាំ ជាមន្ត្រីសុខាភិបាល ទៅរដ្ឋបាលខេត្តប៉ៃលិន ដើម្បីចាត់ការអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន។

**យោង** ៖- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- សេចក្តីណែនាំលេខ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ សេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកជំទាវអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ជ្រាបថា កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ក្រសួងមុខងារសាធារណៈបានទទួលពាក្យបណ្តឹងតវ៉ា របស់លោក **ខឹម មុនីកុសល** ភេទប្រុស អាយុ៤៨ឆ្នាំ ជាមន្ត្រីសុខាភិបាលនៅការិយាល័យបង្ការនិងគ្រប់គ្រងជំងឺនៃមន្ទីរសុខាភិបាលខេត្តប៉ៃលិន ដែលបានដាក់ពាក្យប្តឹងជំទាស់នឹងដីកាលេខ០១៨/២១ ដក.តត របស់រដ្ឋបាលខេត្តប៉ៃលិន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ស្តីពីការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២។

អនុលោមមាត្រា៦៧ដល់មាត្រា៧០ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ខ្ញុំសូមបង្វែរពាក្យបណ្តឹងតវ៉ានេះ ទៅរដ្ឋបាលខេត្តប៉ៃលិន ដើម្បីបង្កើតគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈខេត្តប៉ៃលិន ក្នុងការដោះស្រាយករណីនេះឱ្យស្របតាម គោលការណ៍ បែបបទ និងនីតិវិធី ដែលមានជាធរមាន។

អាស្រ័យហេតុនេះ សូម **លោកជំទាវអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន** ចាត់ចែងអនុវត្តនិងដោះស្រាយឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ថ្ងៃ សុក្រ ១៣កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ក្រសួងមុខងារសាធារណៈ

ព្រុំ សុខា

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
" ដើម្បីជូនជ្រាប "
- មន្ទីរមុខងារសាធារណៈខេត្តប៉ៃលិន " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh